បណ្ណាគារភក្ដីឡជ៍
PHEAKDEYLAW BOOK STORE

លេខ : ០៥ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការបង្កើតស្ថានឯកអគ្គរាជទូត
# នៃព្រះរាជាណាចក្រកម្ពុជា
# ប្រចាំសាធារណរដ្ឋសិង្ហបុរី

# ១៩៩៧

ផលិតជាសៀវភៅអេឡិចត្រូនិចដោយបណ្ណាគារភក្ដីឡជ៍

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៧

**អនុក្រឹត្យលេខ ០៥ អនក្រ.បក.**

**ស្តីពីការបង្កើតស្ថានឯកអគ្គរាជទូតនៃ**

**ព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋសិង្ហបូរី**

* * *

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦.១០ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**សំរេច**

មាត្រា ១ : បង្កើតស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋសិង្ហបូរី ដោយមានទីរសែនដ្ឋាន់នៅក្រុងសិង្ហបូរី ។

មាត្រា ២ : ស្ថានឯកអគ្គរាជទូតនេះ ត្រូវដឹកនាំដោយប្រធានបេសកកម្មទូតម្នាក់ ដែលមានឋានៈជាឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាព ឬ ជាអគ្គទីប្រឹក្សា និង ជាភារ ធារី ។

មាត្រា ៣ : សមាសភាពមន្ត្រីការទូតផ្សេងទៀត យ៉ាងច្រើនបំផុតបួននាក់ នឹងត្រូវកំណត់តាមលក្ខការណ៍ការទូត នៃព្រះរាជាណាចក្រកម្ពុជា ។ រីឯបុគ្គលិកមិនមែនការទូតទាំងឡាយ នឹងត្រូវកំណត់ដោយរដ្ឋមន្ត្រីការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ៤ : មន្ត្រីការទូតតំណាងសេដ្ឋកិច្ច ពាណិជ្ជកម្ម ត្រូវជ្រើសតាំងយកអ្នកមានជំនាញពីមួយ នាក់ទៅពីរនាក់ ។

មាត្រា ៥ : ប្រព័ន្ធហិរញ្ញកិច្ចសំរាប់មន្ត្រី និងបុគ្គលិកនៃស្ថានឯកអគ្គរាជទូតនេះ នឹងស្ថិតក្នុងប្រភេទ « ខ » ។

មាត្រា ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីពាណិជ្ជកម្ម រដ្ឋមន្ត្រីសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការមុខងារសាធារណៈ ត្រូវទទួលបន្ទុករៀងៗ ខ្លួន អនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| **ព្រះហស្តលេខា និង ត្រា** | **ហត្ថលេខា និងត្រា** |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *